អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែង គម្របដបឥន្ទធនូ**
**ចិត្តចលភាព**
បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។
**សិក្សាសង្គម**
គំនូរ និងសកម្មភាពកសាង (ការយល់ដឹង ការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព)។
**បុរេគណិត**
ទំហំ និងពណ៌ (ចំណាត់ក្រុម និងលំដាប់លំដោយ)។

**គោលបំណង** ៖
**(ចិត្តចលភាព)** ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។
**(សិក្សាសង្គម)** ការបង្ហាញពីរសកម្មភាពផ្សេងៗទៀតដែលបានបង្កើតជាស្នាដៃ។
**(បុរេគណិត)** ប្រាប់បានពីរបៀបរៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់។

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង “តើនរណាជាអ្នកលាបពណ៌មេឃ?”

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ក្រដាសសម្រាប់បិទធ្វើឥន្ទធនូ ដែលមានទំហំA3 ឬធំជាងហ្នឹងក៏បាន និងគម្របដប៧ពណ៌ (១ឈុត ១ក្រុម) ។

**ការរៀបចំ** ៖ ក្រដាសសម្រាប់បិទធ្វើរូបឥន្ទធនូ ចែកគម្របដបតាមក្រុម ។

**សេចក្តីណែនាំ**៖

1. ថ្ងៃនេះអ្នកគ្រូនឹងលេងល្បែងគម្របដបឥន្ទធនូ ជាមួយកូនៗទាំងអស់គ្នា។
2. សួរក្មេងៗថា៖ តើកូនៗស្គាល់ឥន្ទធនូដែរឬទេ? បាទ/ចាស ស្គាល់
3. តើឥន្ទធនូមានរាងយ៉ាងដូចម្តេច? មានរាងកោង រួចធ្វើដៃកោង ហើយក្មេងៗទាំងអស់គ្នាធ្វើតាម។
4. បង្ហាញពណ៌កម្របដបម្តងមួយពណ៌ ហើយឱ្យក្មេងៗថាតាម។
5. បង្ហាញរូបភាព ឥន្ទធនូដែលបានធ្វើរួចទៅកាន់កុមារទាំងអស់។
6. ឥឡូវអ្នកគ្រូនឹងយកគម្របដបឱ្យកូនៗបង្កើតជាឥន្ទធនូ។
7. ប្រាប់ពួកគេពីរបៀបនៃការធ្វើវា
   - ➔ ឥន្ទធនូមាន៧ពណ៌ ដូច្នេះត្រូវមានគម្របដបដែលមានពណ៌ទាំង៧ដូចគ្នា។
   - ➔ តម្រៀបគម្របដបទៅតាមពណ៌តាមលំសដាប់នៃពណ៌របស់ឥន្ទធនូ
   - ➔ លំដាប់ពណ៌ គឺពណ៌ក្រហម ទឹកក្រូច លឿង បៃតង ខៀវ ស្វាយ និងខៀវស្វាយ។

- ➔ យើងអាចឱ្យក្មេងៗតម្រៀបគម្របដបម្នាក់មួយៗ
  ឬតាមតាមពណ៌ៗរបស់អ្នកបានចែកឱ្យពួកគេក៏បានដែរ
- ➔ ពេលដែលបិទយើងឱ្យពួកគេប្រើកាវស្អិត ឬកាវបាយម៉ានក៏បានបើមាន។
- ➔ ការធ្វើឥន្ទធនូនេះជាធ្វើជាក្រុមមួយថ្នាក់តែម្តងបាន
  ព្រោះពួកគេអាចទុកវាជាស្នាដៃប្រចាំថ្នាក់បាន និងបិតនៅក្នុងថ្នាក់ក៏ល្អ។
- ➔ ល្បែងនេះ គ្រាន់តែលេងឱ្យក្មេងៗរៀបរូបភាពឥន្ទធនូគឺជាការស្រេចតែម្តង។